# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៣៧២សហវ.វស

## ប្រកាស

**ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីចុះពិនិត្យវាយតំលៃ**
**លើផលប៉ះពាល់ដល់ប្រជារាស្ត្រ ពីគំរោងសាងសង់កំណាត់ផ្លូវជាតិ**
**លេខ ២ ពីទីរួមខេត្តតាកែវ ( អូរចំបក់ ) ទៅព្រំប្រទល់**
**កម្ពុជា-វៀតណាម ( ភ្នំដិន )**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខនស.រកត.១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

-បានឃើញលិខិតលេខ ៧០៦សក ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០២ របស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន ។

-បានឃើញលិខិតលេខ ១៥០១ សហវ.វស ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-បានឃើញលិខិតលេខ ៨៣២ សក ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០២ របស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន ។

-យោងតាមតំរូវការចាំបាច់នៃការងារ

## សំរេច

**ប្រការ ១:** បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីចុះពិនិត្យវាយតំលៃលើផលប៉ះពាល់ដល់ប្រជារាស្ត្រពីគំរោងសាងសង់កំណាត់ផ្លូវជាតិ លេខ ២ ពីទីរួមខេត្តតាកែវ ( អូរចំបក់ ) ទៅព្រំប្រទល់កម្ពុជា-វៀតណាម ( ភ្នំដិន ) ។

**ប្រការ ២:** គណៈកម្មការអន្តរក្រសួងនេះ មានសមាសភាពដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១. ឯកឧត្តម ញាណ ឡេង | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | ជាប្រធាន |
| ២. លោក ចាន់ សុធី | ប្រធាននាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៣. លោក ចៅ យុទ្ធថា | ប្រធានការិយាល័យសហប្រតិបត្តិការទ្វេភាគី | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៤. លោក បែន ដារ៉ាមុនី | អនុប្រធានការិយាល័យសហប្រតិបត្តិការទ្វេភាគី | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៥. លោក ជិន រ័ត្នមុនី | ជំនួយការឯកឧត្តមប្រធានគណៈកម្មការអន្តរក្រសួង | | សមាជិក |
| ៦. លោកស្រី អ៊ុក សុមាលី | មន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន | | សមាជិក |
| ៧. លោក ខាន់ រ៉ា | មន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន | | សមាជិក |
| ៨. លោក យស់ សុវណ្ណា | មន្ត្រីការិយាល័យសហប្រតិបត្តិការទ្វេភាគី | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax 855-23-427 798

| | | | |
|---|---|---|---|
| ៩. លោក សារុម សុធឿន | មន្ត្រីការិយាល័យសហប្រតិបត្តិការទ្វេភាគី | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១០. លោក ឃុន ផលគង់ | មន្ត្រីនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ ៣:** គណៈកម្មការអន្តរក្រសួង មានភារកិច្ចចុះពិនិត្យដល់ទីកន្លែងធ្វើស្ថិតិលើផលប៉ះពាល់ដល់ប្រជារាស្ត្រដែលស្ថិតនៅតាមគំរោងសាងសង់កំណាត់ផ្លូវជាតិលេខ ២ ពីទីរួមខេត្តតាកែវ ( អូរចំបក់ )ទៅព្រំប្រទល់កម្ពុជា-វៀតណាម ( ភ្នំដិន ) រួចហើយធ្វើការវាយតំលៃអោយបានសមស្រប ដើម្បីមានមូលដ្ឋានក្នុងការចំណាយថវិកាបដិភាគសំរាប់គំរោងការនេះ ។

**ប្រការ ៤:** ក្រសួងសាធារណៈការ និង ដឹកជញ្ជូន នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង មន្ត្រីដូចមានចែងក្នុងប្រការ ២ មានភារកិច្ចអនុវត្តន៍ប្រកាសនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២២ខែឧសភា ឆ្នាំ ២០០២

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គាត ឈន់**

**ចំលងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសាធារណៈការ និងដឹកជញ្ជូន
- ដូចប្រការ៤
- ឯកសារ-កាលប្បវត្តិ